ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

ល.ខ ០៤៤ ...ប្រកស/ស.ក

រាជធានីភ្នំពេញ, ថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ២០០៧

# ប្រកាស

## ស្តីពី

## ការសរសេរផ្លាកសញ្ញាសំគាល់ថ្មីសម្រាប់មន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិ និងអង្គភាពដែលទទួលការពិគ្រោះឬព្យាបាលជំងឺ

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ មករា ១៩៩៦ ប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០២/១១២ ចុះថ្ងៃទី០៦ ឧសភា ២០០២ ស្តីពីការប្រើប្រាស់ និងការពារបដិរូបកាកបាទក្រហម អឌ្ឍច័ន្ទក្រហម
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ តុលា ១៩៩៧ ស្តីពីការរៀបចំប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- យោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល

## សម្រេច

**ប្រការ ១.-** បង្កើតផ្លាកសញ្ញាសំគាល់ថ្មីសម្រាប់ដាក់សំគាល់នៅលើក្លោងទ្វារបងច្រកចូល មន្ទីរពេទ្យជាតិ មជ្ឈមណ្ឌល ជាតិ អង្គភាពដែលទទួលពិគ្រោះជំងឺ ឬ ព្យាបាលជំងឺ ។

**ប្រការ ២.-** ផ្លាកសញ្ញាសំគាល់ថ្មីនេះមានបីពណ៌ :

- ពណ៌ស : តំណាងទឹកចិត្តស្មោះត្រង់នឹងអ្នកជំងឺ ព្រមទាំងអនាម័យល្អ ។
- ពណ៌ក្រហម : តំណាងទឹកចិត្តមុះមុតក្នុងការបម្រើសុខភាពជូនប្រជាជន និង សង្គ្រោះការបាត់បង់លោហិតនៃអ្នកជំងឺ ។

- ពណ៌ខៀវ : តំណាងទឹកចិត្តមនុស្សធម៌ សមធម៌ សង្គ្រោះជីវិត ដោយមិនរើសអើងពូជសាសន៍ មិនប្រកាន់វណ្ណៈ និង និន្នាការនយោបាយអ្វីឡើយ ។

ប្រការ ៣.- ផ្លាកសញ្ញាមន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិ អង្គភាពដែលទទួលការពិគ្រោះជំងឺ ឬព្យាបាលជំងឺនេះមានទំហំអាចប្រែប្រួលសមស្របទៅតាមទីតាំងជាក់ស្តែងតែយ៉ាងតូចបំផុត :

- បណ្តោយប្រវែង ៥១០ ស.ម
- ទទឹងប្រវែង ៦០ ស.ម
- ទំហំតួអក្សរខ្មែរសរសេរចំកណ្តាលពណ៌ខៀវទឹកប៊ិច កំពស់អក្សរ ២០ ស.ម
- ទំហំតួអក្សរឡាតាំងសរសេរចំកណ្តាលពណ៌ខៀវទឹកប៊ិច កំពស់អក្សរ ១២ ស.ម
- នៅសងខាងមាន Logo រង្វង់មូលពណ៌ក្រហមដែលមានអង្កត់ផ្ចិតសមស្របទៅនឹងទំហំផ្លាកសញ្ញា នៅចំកណ្តាលមានសញ្ញាកាកបាទពណ៌ស មានអក្សរ H ពណ៌ខៀវទឹកប៊ិចចំកណ្តាល
- ផ្ទៃផ្លាកសញ្ញាពណ៌ស ។

ប្រការ ៤.- អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុក្រសួងសុខាភិបាល អគ្គាធិការដ្ឋានក្រសួងសុខាភិបាល នាយកដ្ឋានមន្ទីរពេទ្យ មន្ទីរសុខាភិបាលរាជធានី និង ខេត្ត-ក្រុង គ្រប់មន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិ អង្គភាព ដែលទទួលការពិគ្រោះជំងឺ ឬព្យាបាលជំងឺទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៥.- រាល់លិខិតបទដ្ឋានណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

ប្រការ ៦.- ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ្ជ. នុត-សុខុម

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ដូចមានចែងក្នុងប្រការ ៤
  (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ


មជ្ឈមណ្ឌលជាតិគាំពារមាតា និង ទារក
National Maternal and Child Health Center
H
10cm
20cm
13cm
12cm
5cm
ទទឹងផ្ទាំង 60 cm
មន្ទីរពេទ្យកុមារជាតិ
National Pediatric Hospital
ទទឹងផ្ទាំង 60 cm